**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ៩៩៦/១៣-១១-២០១៣

**សាលដីកា**

លេខ០៩ក្រVIយ

ចុះថ្ងៃទី០៦-០២-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៧-០១-២០១៤ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

**លោក** [redacted]

**លោក** [redacted]

**លោក** [redacted]

**តំណាងមហាអយ្យការ**

**លោក**-[redacted]

**ក្រឡាបញ្ជី**

**លោកស្រី** [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៩៩៦ចុះថ្ងៃទី១៣-១១-២០១៣រវាង៖

**១-ជនជាប់ចោទឈ្មោះ** [redacted] **ចមុល(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរអតីតនាយកធនាគារកាណាឌីយ៉ាសាខាអ្នកលឿង កើតនៅភូមិបុស្ស ឃុំដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប មានទីលំនៅសព្វថ្ងៃ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ។ទោសពីមុនគ្មាន ។ឃុំខ្លួនថ្ងៃទី០២.០១.២០១៣។**មានមេធាវ** [redacted] **ស្វរិយា.**



៣០៤

Scanned with CamScanner

**២-ជនជាប់ចោទឈ្មោះ** [redacted] **ចិន្តា(ចុងបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរអតីតបុគ្គលិកធនាគារកាណាឌីយ៉ាសាខាអ្នកលឿង កើតនៅ និង ទីលំនៅសព្វថ្ងៃ [redacted] នៅលីវ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ។ទោសពីមុនគ្មាន ។ក្រៅឃុំ។

ត្រូវចោទពីបទ រំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៣នៃក្រមព្រហ្មទណ្ឌ។

**៣-ជនជាប់ចោទឈ្មោះ** [redacted] **សុខា(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ កើតនៅភូមិបឹងកុក ឃុំបឹងកុក ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះជួលក្នុង [redacted] ផ្លូវលេខ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន៤នាក់ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted] (រ) ។ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី០២.០១.២០១៣។**មានមេធាវី** [redacted] **សំអឿន.**

ជាប់ចោទពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៩ និង មាត្រា៤០០នៃក្រមព្រហ្មទណ្ឌ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អគ្គនាយកធនាគារកាណាឌីយ៉ា ក.អ(ចុងបណ្តឹងឧទ្ធរណ៍)** អាស័យដ្ឋានលេខ៣១៥ វិថីព្រះអង្គដួង កែងនឹងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។**មានមេធាវី** [redacted] **ចំណាន.**

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១០-២០១៣របស់ឈ្មោះ [redacted] វិបុល មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-១០-២០១៣របស់លោក [redacted] ព្រះរាជអាជ្ញារង មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង ត្រង់ចំណុចទី១ និង ទី៣ នៃសេចក្តីសំរេច។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-១០-២០១៣របស់ឈ្មោះ [redacted] សុខា មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**ដំណើររឿងមានដូចតទៅ:**

តាមពាក្យបណ្តឹងចុះថ្ងៃទី១៩-០២-២០១២របស់អគ្គនាយកធនាគារកាណាឌីយ៉ា ក.អ



៣០៥

Scanned with CamScanner

អ សុំប្តឹងឈ្មោះ[redacted]វិបុល មានមុខរបរជានាយកគ្រប់គ្រងធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ពីបទរំលោភលើទំនុកចិត្ត ព្រមទាំងគូកន។ ដោយសំអាងហេតុថា ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០១២រហូតដល់បច្ចុប្បន្ននេះ ឈ្មោះ[redacted]វិបុល ព្រមទាំងគូកនបានឃុបឃិតគ្នាលួចយកប្រាក់ចំនួន៩៦០.០០០ដុល្លាអាមេរិច(បួនរយហុកសិបពាន់ដុល្លាអាមេរិក)ពីធនាគារកាណាឌីយ៉ាសាខាអ្នកលឿង។ សំណូមពរ៖

១-សុំឃុំខ្លួនជនល្មើសព្រមទាំងគូកន និង ផ្តន្ទាទោសតាមច្បាប់។

២-ទាមទារប្រាក់ចំនួន៩៦០.០០០ដុល្លាអាមេរិច(បួនរយហុកសិបពាន់ដុល្លាអាមេរិច)ពីឈ្មោះ[redacted]វិបុល។

៣-សុំទាមទារជំងឺចិត្តចំនួន៥០.០០០ដុល្លាអាមេរិច(ហាសិបពាន់ដុល្លាអាមេរិច)ពីឈ្មោះ[redacted]វិបុល។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង សំរេចសេចក្តីដូចតទៅ៖

១-ឲ្យឈ្មោះ[redacted] ចិន្តា រួចផុតពីបទចោទប្រកាន់ ពីបទ រំលោភទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀតប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១ តាមដីកាសំរេចបញ្ជូនរឿងទៅជំនុំជំរះលេខ២៧៥/២០១៣ចុះថ្ងៃទី២១-៥-២០១៣របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ដោយផ្អែកតាមមាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]វិបុល ភេទប្រុស អាយុ៣៨ឆ្នាំ (សាវតាជាតិដូចខាងលើ)ដាក់ពន្ធនាគារកំណត់០២ឆ្នាំ(ពីរឆ្នាំ)។

-ឲ្យឈ្មោះ[redacted]វិបុល សងប្រាក់ចំនួន៦០.០០០(ប្រាំមួយម៉ឺន)ដុល្លាអាមេរិកទៅឲ្យដើមបណ្តឹងក្រុមហ៊ុនអាស៊ីអា អ៊ិនស្វូរិន(ខេមបូឌា)ភីអិលស៊ី។

-ឲ្យឈ្មោះ[redacted]វិបុល បង់សំណងជំងឺចិត្តជាប្រាក់ចំនួន២០.០០០(ពីរម៉ឺន)ដុល្លាអាមេរិកទៅឲ្យដើមបណ្តឹងក្រុមហ៊ុនអាស៊ីអា អ៊ិនស្វូរិន(ខេមបូឌា)ភីអិលស៊ី។ការទាមទារលើសពីនេះច្រានចោល។

ពីបទ រំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀតប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១។បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៣នៃក្រមព្រហ្មទណ្ឌ។

៣-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted] សុខា ភេទប្រុស អាយុ៥០ឆ្នាំ (សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល០២(ពីរ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ។

-ឲ្យឈ្មោះ[redacted] សុខា សងប្រាក់ចំនួន៤០០.០០០(សែសិបម៉ឺន)ដុល្លាអាមេរិកទៅឲ្យដើមបណ្តឹងក្រុមហ៊ុនអាស៊ីអា អ៊ិនស្វូរិន(ខេមបូឌា)ភីអិលស៊ី។

-ឲ្យឈ្មោះ[redacted]សុខា បង់សំណងជំងឺចិត្តជាប្រាក់ចំនួន២០.០០០(ពីរម៉ឺន)ដុល្លាអា

បើកទៅឲ្យដើមបណ្តឹងក្រុមហ៊ុនអាស៊ីអា អ៊ិនសួរិន(ខេមបូឌា)គីអិលស៊ី។ការទាមទារ លើសពីនេះច្រានចោល។

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៩ និង មាត្រា៤០០ក្រមព្រហ្មទណ្ឌ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៧១/១៧-០២-២០១២របស់សាលាដំបូងខេត្តព្រៃវែង ទៅឲ្យតំណាងមហាអយ្យការអមសាលាដំបូងខេត្តព្រៃវែងដើម្បីបើកការស៊ើបសួរលើឈ្មោះ [redacted] សុវណ្ណ ហៅ វ៉ាត ភេទ ប្រុស សព្វថ្ងៃនៅផ្ទះលេខ [redacted] ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៩ និង មាត្រា៤០០ក្រមព្រហ្មទណ្ឌ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំង ៣ និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមកំណត់ច្បាប់។

**ច្បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១០-២០១៣របស់ឈ្មោះលាស់ វិបុល មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**ច្បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-១០-២០១៣របស់លោក [redacted] ព្រះរាជអាជ្ញារង មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង ត្រង់ចំណុចទី១ និង ទី៣ នៃសេចក្តីសំរេច។

**ច្បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-១០-២០១៣របស់ឈ្មោះ [redacted] សុខា មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍.

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ចៅក្រមអានរបាយការណ៍.

*ជនជាប់ចោទឈ្មោះ* [redacted] *វិបុល ឆ្លើយថា៖*ខ្លួនមានអាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរអតីតនាយកធនាគារកាណាឌីយ៉ាសាខាអ្នកលឿង កើតនៅភូមិបុស្ស ឃុំដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប មានទីលំនៅសព្វថ្ងៃ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ឪពុកឈ្មោះ [redacted](ស) ម្តាយ



៣១៧

ឈ្មោះ[redacted] (រ) ។ទោសពីមុនគ្មាន ។ឃុំខ្លួនថ្ងៃទី០២.០១.២០១៣។ពីមុនខ្លួនបានប្ដឹងឧទ្ធរណ៍ តែខ្លួនបានសុំដកពាក្យបណ្ដឹងឧទ្ធរណ៍វិញ ខ្លួនមិនបានសុំយោបល់ពីមេធាវីខ្លួនទេ ឥឡូវខ្លួនសុំដកបណ្ដឹងឧទ្ធរណ៍ ដើម្បីសុំតុលាការជំនុំជំរះ និង បន្ធូរបន្ថយទោសដល់ខ្លួន។នៅសាលាដំបូងខ្លួនបានឆ្លើយរួចហើយ ខ្លួនសុំធានាចំលើយរបស់ខ្លួនថាជាការពិត។ខ្លួនបានប្រាប់គាត់ថា លុយនេះជារបស់ធនាគារ អាចខ្ចីបានត្រឹមតែ២អាទិត្យប៉ុណ្ណោះ ។ខ្លួនដកប្រាក់ចេញពីធនាគារមិនឆ្លងកាត់ឈ្មោះវ៉ា ចិន្ដាទេ។ខ្លួនបានប្រាប់គាត់ថាលុយជារបស់ធនាគារ ។ខ្លួនមិនបាននិយាយថាលុយនេះជារបស់អតិថិជនវៀតណាមទេ។កិច្ចសន្យាដើមនៅខ្លួនទុក កិច្ចសន្យាធ្វើតែ១ច្បាប់។ខ្លួនបានប្រគល់លុយឲ្យឈ្មោះ[redacted] សុខា ផ្ទាល់។ខ្លួនបានដកលុយពីធនាគារចំនួន៤៦០.០០០ដុល្លាអាមេរិក(សែសិបប្រាំមួយម៉ឺនដុល្លាអាមេរិក) ខ្លួនប្រគល់ឲ្យឈ្មោះ[redacted] សុខាទាំងអស់ ប្រគល់ឲ្យ២លើក។ខ្លួនឲ្យលុយឈ្មោះ[redacted]សុខា ខ្ចីគឺខ្លួនមិនបានគិតការប្រាក់ និង កាត់ទឹក១០%ពីគាត់ ដូចគាត់និយាយទេ។លុយនេះមិនទាន់បញ្ចូលក្នុងទូដែកទេ គឺទុកនៅក្នុងបន្ទប់ធ្វើការរបស់ខ្លួនគណនេយ្យ និង អ្នកត្រួតពិនិត្យមិនទាន់បានដឹងទេ។ទូដែកនេះពេលខ្លួនអវត្តមានទើបឈ្មោះវ៉ា ចិន្ដាមានសិទ្ធិទទួលបន្តពីខ្លួន។លុយបើចូលក្នុងទូដែកហើយ ខ្លួន ឬឈ្មោះវ៉ា ចិន្ដាអាចដកលុយបាន លុះត្រាមានខាងគណនេយ្យ និង ខាងត្រួតពិនិត្យចូលរួមផង។កិច្ចសន្យាខ្លួនបានពីឈ្មោះ[redacted] សុវណ្ណសរសេរឲ្យ ។កិច្ចសន្យាដាក់ថាខ្ចីលុយចំនួន៥៥០.០០០ដុល្លាអាមេរិក(ហាសិបប្រាំម៉ឺនដុល្លាអាមេរិក) តែឲ្យលុយចំនួន៤៦០.០០០ដុល្លាអាមេរិក(សែសិបប្រាំមួយម៉ឺនដុល្លាអាមេរិក) ឯចំនួន១០០.០០០ដុល្លាអាមេរិក(ដប់ម៉ឺនដុល្លាអាមេរិក)ទៀត គឺជាអត្ថប្រយោជន៍ដែលឈ្មោះ[redacted] សុខា ត្រូវឲ្យមកខ្លួន។សំណូមពរសុំតុលាការសំរេចបន្ធូរបន្ថយទោសដល់ខ្លួនឲ្យបានទាប សុំបង្គាប់ឲ្យឈ្មោះ[redacted] សុខាសងការខូចខាតទាំងអស់មកធនាគារកាណាឌីយ៉ាតាមរយៈក្រុមហ៊ុនអេស៊ីអាអិនស្វ៊ីរិនខេមបូឌា ភីអិលស៊ី និង សុំឲ្យឈ្មោះ[redacted] សុខា សងចំនួន១០០.០០០ដុល្លាអាមេរិក(ដប់ម៉ឺនដុល្លាអាមេរិក)មកមកធនាគារកាណាឌីយ៉ា។

*ជនជាប់ចោទឈ្មោះ[redacted] សុខា ឆ្លើយថា៖* ខ្លួនមានអាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ កើតនៅភូមិបឹងកុក ឃុំបឹងកុក ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះជួលក្នុង[redacted]ប្រពន្ធឈ្មោះ[redacted] មានកូន៤នាក់ ឪពុកឈ្មោះ [redacted](ស) ម្ដាយឈ្មោះ[redacted] (រ) ។ទោសពីមុនគ្មាន ។ឃុំខ្លួនថ្ងៃទី០២.០១.២០១៣។មានមេធាវី [redacted] សំអឿន។ខ្លួនប្ដឹងឧទ្ធរណ៍មិនសុខចិត្តត្រង់ចំណុចដាក់ទោសខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមិនសុខចិត្តនឹងសាលក្រមទាំងមូល ដែលសរសេរហួសពីការពិត ។ខ្លួនមិនបានដឹងថាឈ្មោះ[redacted] វិបុលលួចលុយពីធនាគារមកឲ្យខ្លួនខ្ចីទេ ព្រោះគាត់ចង់បានប្រាក់កុំមុយស្យុង១០% និង ការប្រាក់២,៥%ពីខ្លួន។ខ្លួនពិតបានទទួលប្រាក់លើកទី១ពីឈ្មោះ[redacted] វិបុលចំនួន២០០.០០០ដុ



Scanned with CamScanner

ល្លារអាមេរិក(ម្ភៃម៉ឺនដុល្លាអាមេរិក)ខ្លួនបានចារថាបានទទួលចំនួន២០០.០០០ដុល្លាអាមេរិក(ម្ភៃម៉ឺនដុល្លាអាមេរិក)។លើកទី២គាត់ប្រាប់ថាលុយចំនួន២០០.០០០ដុល្លាអាមេរិក(ម្ភៃម៉ឺនដុល្លាអាមេរិក) តែពេលខ្លួនរាប់ទៅឃើញមានលុយតែចំនួន១៦០.០០០ដុល្លាអាមេរិក(ដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក)ប៉ុណ្ណោះ ហើយឈ្មោះ[redacted] វិបុលគាត់ថាលុយចំនួន៤០.០០០ដុល្លាអាមេរិក(បួនម៉ឺនដុល្លាអាមេរិក)ទៀត គឺជាលុយដែលគាត់ដកទឹក១០% តែខ្លួនបានចារថាបានទទួលចំនួន២០០.០០០ដុល្លាអាមេរិក(ម្ភៃម៉ឺនដុល្លាអាមេរិក)ទៀត។ ខ្លួនមិនបានដឹងថាជាលុយរបស់ធនាគារទេ គាត់ប្រាប់ខ្លួនថាលុយនេះជារបស់អតិថជនវៀតណាម គាត់គ្រាន់តែជាអ្នកធានា និង បានទឹក១០%ប៉ុណ្ណោះ។ដំបូងខ្លួននិយាយសុំខ្ចីគាត់រយៈពេល៣ខែទៅ៦ខែ តែក្នុងកិច្ចសន្យាដាក់ថា១ខែទៅវិញ ក្នុងកិច្ចសន្យាគឺធ្វើបែបឯកជន មិនមានស្នាមមេដៃម្ចាស់លុយទេ គឺមានតែស្នាមមេដៃរបស់ខ្លួនប៉ុណ្ណោះ កិច្ចសន្យាដើមនៅឈ្មោះ[redacted]វិបុល ខ្លួនបានឲ្យគាត់ផ្តិតមេដៃដែរ តែគាត់ថាយកកិច្ចសន្យានេះទៅថតសិន ចាំគាត់ផ្តិតមេដៃឲ្យខ្លួន ព្រោះកិច្ចសន្យាធ្វើតែ១ច្បាប់ប៉ុណ្ណោះ ខ្លួនបានត្រៀមថានឹងយកកិច្ចសន្យានេះឲ្យមេធាវីជួយពិនិត្យដែរ តែគាត់យកកិច្ចសន្យានោះទៅបាត់ គាត់មិនបានឲ្យខ្លួនទេ។ក្រោយមកមិនទាន់បាន១ខែផងគាត់ប្រាប់ឲ្យខ្លួនរកប្រាក់មកបង្វិលឲ្យគាត់វិញ។កន្លងមកខ្លួនមិនដែលខ្ចីប្រាក់ពីធនាគារទេ។លុយដែលខ្ចីនេះខ្លួនសុខចិត្តសងវិញទាំងអស់ ព្រោះខ្លួនបានទំនាក់ទំនងជាក្រុមហ៊ុនគេរួចហើយ។កិច្ចសន្យានេះខ្លួនបានឃើញនៅលោកចៅក្រម[redacted]ពលដែលគាត់កំពុងសាកសួរយកចំលើយ។ខ្លួនបានសួរឈ្មោះ[redacted] វិបុលពីចំនួនលុយក្នុងកិច្ចសន្យាសរសេរដាក់ដល់ទៅចំនួន៥៥០.០០០ដុល្លាអាមេរិក(ហាសិបប្រាំម៉ឺនដុល្លាអាមេរិក) តែខ្លួនទទួលបានតែចំនួន៤០០.០០០ដុល្លាអាមេរិក(សែសិបម៉ឺនដុល្លាអាមេរិក)ប៉ុណ្ណោះ ខ្លួនក៏សួរឈ្មោះ[redacted] វិបុលៗឆ្លើយថា ចាំអតិថិជនវៀតណាមប្រគល់ឲ្យប៉ុន្មាន ចាំផ្តិតមេដៃទទួលចំនួនប៉ុណ្ណោះទៅ។ខ្លួនមិនដែលបានសន្យាថាឲ្យលុយទៅឈ្មោះ[redacted]វិបុលចំនួន១០០.០០០ដុល្លាអាមេរិក(ដប់ម៉ឺនដុល្លាអាមេរិក)ទេ ព្រោះគាត់បានដកទឹក១០%រួចហើយ ។សំណូមពរសុំតុលាការសំរេចលើកលែងចោទប្រកាន់ និង សុំដោះលែងខ្លួន ឲ្យមានសេរីភាពវិញ។

*តំណាងមហាអយ្យការសន្និដ្ឋានថា៖* ក្នុងសំណុំរឿងនេះ ព្រះរាជអាជ្ញារងបានប្តឹងឧទ្ធរណ៍ត្រង់ចំណុចទី១ និង ទី៣។ពេលសវនាការនេះចំលើយរបស់ជនជាប់ចោទទាំង២ឆ្លើយស៊ីសង្វាក់ទៅកំណត់ហេតុនានា បញ្ជាក់ថាឈ្មោះ[redacted] ចិន្តា មិនពាក់ព័ន្ធនឹងបទល្មើសរំលោភទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀតទេ សុំតំកល់សេចក្តីសំរេចចំណុចទី១ទុកជាបានការ ដែលឲ្យឈ្មោះ[redacted] ចិន្តា រួចផុតពីបទចោទប្រកាន់។ចំពោះចំណុចទី៣ ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញារង ដោយសំអាងថា ពុំអាចសន្និដ្ឋានចោទប្រកាន់លើឈ្មោះ[redacted] សុខា បានព្រោះទើបតែលេចចេញនូវអង្គហេតុថ្មី តែសេចក្តីសំរេចបានផ្តន្ទាទោសឈ្មោះបេន សុខារួចហើយ ។សុំសំរេចតំកល់សាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងនេះទុកជាបានការ ។



៣០៩

*មេធាវី* [redacted] *ចំណាន សន្និដ្ឋានថា៖*ខ្លួនជាមេធាវីតំណាងឲ្យក្រុមហ៊ុនអេស៊ីអា អិនស៊ូរិន ខេមបូឌា ភីអិលស៊ី។កិច្ចសន្យានេះ ដាក់ថាជាតំណាងធនាគារកាណាឌីយ៉ា ឈ្មោះ [redacted] សុខាគាត់ដឹងច្បាស់ថា ឈ្មោះ [redacted] វិបុលបានលួចប្រាក់ពីធនាគារមែន។ក្រោយពីបានទទួលប្រាក់រួចហើយ ឈ្មោះ [redacted] សុខាគាត់បានផ្លាស់ប្តូរទីលំនៅ និង មានចេតនាគេសវេសមិនព្រមសងប្រាក់ទៅឲ្យឈ្មោះ [redacted] វិបុលវិញទេ។តែចំលើយរបស់ឈ្មោះ [redacted] សុខា ឆ្លើយពេលសវនាការបញ្ជាក់ថាលុយនេះជារបស់អតិថិជនវៀតណាមទៅវិញ តែតាមពិតគាត់ដឹងថាលុយនេះជាលុយខុសច្បាប់។សំណូមពរសុំតំកល់សាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងនេះទុកជាបានការ ។

*មេធាវី* [redacted] *សុរិយា សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] វិបុល ។កូនក្តីខ្លួនបានសារភាពថា គាត់ពិតជាបានដកលុយដោយខុសច្បាប់ចេញពីធនាគារ តែផលប្រយោជន៍ទាំងអស់នេះបានផ្តល់ឲ្យឈ្មោះ [redacted] សុខា នេះបញ្ជាក់ថាកូនក្តីខ្លួនពុំបានទទួលប្រយោជន៍អ្វីទេ យោងតាមមាត្រា៣៩១នៃក្រមនីតិវិធី។កូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ សំណូមពរតុលាការសំរាលទោសដល់កូនក្តីខ្លួនឲ្យបានទាបផង។

*មេធាវី* [redacted] *សំអឿន សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] សុខា។កូនក្តីខ្លួនពិតជាមិនដឹងថាលុយនេះរបស់ធនាគារកាណាឌីយ៉ាទេ ហើយកូនក្តីខ្លួនសំអាងថានឹងឲ្យមេធាវីជួយពិនិត្យ ទើបមិនបានយកចិត្តទុកដាក់លើកិច្ចសន្យានេះ កូនក្តីខ្លួនបានជឿជាក់ ថាឈ្មោះ [redacted] វិបុលអាចរកលុយពីអតិថិជនវៀតណាមដែលរកស៊ីចងការប្រាក់បាន។នៅសាលាដំបូងលោកព្រះរាជអាជ្ញារងគាត់ពុំទាន់បានសន្និដ្ឋានចោទប្រកាន់លើឈ្មោះ [redacted] សុខាទេ នេះជាកំហុសនីតិវិធី។យោងតាមមាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានប្រយោជន៍ទៅជនជាប់ចោទ។លុយដែលបានកូនក្តីខ្លួនបានទទួលពីឈ្មោះ [redacted] វិបុលមិនមែនជាបទទទួលផលចោរកម្មទេ ។សំណូមពរសុំបដិសេធសាលក្រមទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងចោល សុំឲ្យលើកលែងចោទប្រកាន់ និង សុំដោះលែងកូនក្តីខ្លួនឈ្មោះ [redacted] សុខា ឲ្យមានសេរីភាពវិញ។

ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ.

ក្រោយពីបានស្តាប់អំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋានការពារ.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១-ក/បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-១០-២០១៣របស់លោក [redacted] ព្រះរាជអាជ្ញារងប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង ត្រង់ចំណុចទី១ និង ទី៣។

ខ/បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១០-២០១៣របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍



Scanned with CamScanner

នឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង គ្រង់ចំណុចទាំងមូល។

គ/បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-១០-២០១៣របស់ឈ្មោះ[redacted] សុខា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២១៨/១០-១០-២០១៣របស់សាលាដំបូងព្រៃវែង គ្រង់ចំណុចទាំងមូល។

បណ្តឹងឧទ្ធរណ៍ទាំងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងមាត្រា៣៨១ និង មាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២-ក្នុងអំឡុងឆ្នាំ២០០៦ឈ្មោះ[redacted] សុខាបានទំនាក់ទំនងស្គាល់គ្នាជាមួយឈ្មោះលាស់ វិបុល កាលនោះឈ្មោះ[redacted]វិបុល ជាប្រធានផ្នែកឥណទាននៃធនាគារកាណាឌីយ៉ាស្នាក់ការកណ្តាល។នៅក្នុងឆ្នាំ២០១១ឈ្មោះ[redacted] សុខា បានឲ្យឈ្មោះ[redacted] វិបុល ដែលត្រូវប្តូរមកបំពេញការងារនៅធនាគារកាណាឌីយ៉ាអ្នកលឿង បានយកប្រាក់ពីធនាគារកាណាឌីយ៉ាអ្នកលឿងមិនស្របច្បាប់ចំនួន៥០០.០០០ដុល្លាអាមេរិច(ហាសិបម៉ឺនដុល្លាអាមេរិច)។ដោយឈ្មោះ[redacted] សុខា ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីខ្ចីប្រាក់ពីធនាគារដោយសន្យាឲ្យការប្រាក់ចំនួន១០០.០០០ដុល្លាអាមេរិច(ដប់ម៉ឺនដុល្លាអាមេរិច) និង អត្ថប្រយោជន៍ផ្សេងៗ។នៅខែ១១ និង ខែ១២ ឆ្នាំ២០១១ឈ្មោះលាស់ វិបុលបានដកប្រាក់ពីធនាគារចំនួន៤៦០.០០០$ ឲ្យឈ្មោះ[redacted]សុខាចំនួន៤០០.០០០$(សែសិបម៉ឺនដុល្លាអាមេរិច)ដោយសន្យាប្រគល់ឲ្យវិញក្នុងរយៈពេល១ខែ ប៉ុន្តែក្រោយពីឈ្មោះ[redacted] សុខាបានទទួលប្រាក់រួច ពុំបានប្រគល់ឲ្យវិញតាមការសន្យាឡើយ។

៣-តាមអង្គហេតុនេះ ឈ្មោះ[redacted] វិបុល ត្រូវបានតុលាការផ្តន្ទាទោសរួច ហើយក៏បានប្តឹងឧទ្ធរណ៍ដែរ ប៉ុន្តែក្នុងដំណាក់កាលសាលាឧទ្ធរណ៍ ជនជាប់ចោទនេះបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ សុខចិត្តទទួលទោសតាមច្បាប់។ប៉ុន្តែនាពេលសវនាការជនជាប់ចោទឈ្មោះនេះ បានសុំដកបណ្តឹងសុំដកឧទ្ធរណ៍ចុះថ្ងៃទី២៦-១១-២០១៣ចេញវិញសុំឲ្យតុលាការបន្ធូរបន្ថយទោសតាមច្បាប់ ចំណុចនេះក្រុមប្រឹក្សាពុំអាចលើកយកមកពិចារណាបានឡើយ។

៤-ជនជាប់ចោទឈ្មោះ[redacted] សុខា ពិតជាបានដឹងយ៉ាងច្បាស់នូវអំពើខុសច្បាប់របស់ឈ្មោះ[redacted] វិបុល ដែលបានយកប្រាក់មិនស្របច្បាប់ពីក្នុងធនាគារកាណាឌីយ៉ាសាខាអ្នកលឿងមកឲ្យខ្លួនខ្ចីចំនួន៤០០.០០០ដុល្លាអាមេរិច(សែសិបម៉ឺនដុល្លាអាមេរិច) ទោះបីជាមានកិច្ចសន្យាខ្ចីប្រាក់ក៏ដោយ។

៥-តាមចំលើយរបស់ឈ្មោះវ៉ា ចិន្តាបានឆ្លើយបំភ្លឺថា ខ្លួនពិតជាពុំបានដឹងពីឈ្មោះ[redacted]វិបុល បានលួចដកប្រាក់ទៅឲ្យឈ្មោះ[redacted]សុខាឡើយ។ព្រោះថាខ្លួនពុំដែលបានដឹងថាឈ្មោះ[redacted]សុខា ធ្លាប់ស្នើសុំខ្ចីប្រាក់ពីធនាគារទេ ហើយក៏ពុំដែលស្គាល់ដែរ។ ម្យ៉ាងទៀត ខ្លួនគ្រាន់តែជាអ្នកប្រមូលប្រាក់ដែលត្រូវបញ្ចូលក្នុងទូដែកប្រចាំថ្ងៃទៅឲ្យឈ្មោះ[redacted]វិបុលតែប៉ុណ្ណោះ។

៦-រឿងក្តីនេះសាលាដំបូងបានលើកសំអាងហេតុនេះមកបញ្ជាក់មានលក្ខណៈគ្រប់គ្រាន់ហើយ ហេតុដូច្នេះសភាព្រហ្មទណ្ឌឯកភាពសំអាងហេតុនេះទាំងស្រុងពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់សារជាថ្មីទៀតឡើយ។

៧-អំពើ និង សកម្មភាពរបស់ឈ្មោះ[redacted] ចិន្តា ពុំមានធាតុផ្សំគ្រប់គ្រាន់ពីបទ រំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១។បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៣នៃក្រមព្រហ្មទណ្ឌឡើយ។

៨-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] វិបុល ពីបទ រំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀតប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១។បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៣នៃក្រមព្រហ្មទណ្ឌ។

៩-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] សុខា ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅធនាគារកាណាឌីយ៉ាសាខាអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០១១ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩៩ និង មាត្រា៤០០នៃក្រមព្រហ្មទណ្ឌ។

១០-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានសន្និដ្ឋានថា៖សុំឲ្យក្រុមប្រឹក្សាពិចារណាសំរេចតាមច្បាប់ ព្រោះបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការប្តឹងឧទ្ធរណ៍លើចំណុចទី៣ នៃសាលក្រម គឺទាក់ទងតែអំពីនីតិវិធីតែប៉ុណ្ណោះ។យោងតាមសារណាបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២១-១០-២០១៣របស់តំណាងអយ្យការខេត្តព្រៃវែង។ដូច្នេះក្រុមប្រឹក្សាពិចារណាសំរេចតាមច្បាប់។

១១-ជនជាប់ចោទឈ្មោះបេន សុខា បានសារភាពទទួលស្គាល់កំហុសឆ្គងរបស់ខ្លួនដែលបានខ្ចីប្រាក់ពីឈ្មោះ[redacted] វិបុល ដែលបានមកអំពើខុសច្បាប់ ហើយខ្លួនសុខចិត្តសងទៅឲ្យម្ចាស់ដើមវិញ។ម្យ៉ាងទៀត ជនជាប់ចោទរូបនេះទើបតែប្រព្រឹត្តបទល្មើសលើកដំបូង គប្បីក្រុមប្រឹក្សាពិចារណា អំពីការបន្ធូរបន្ថយទោសដល់ជនជាប់ចោទរូបនេះផ្អែកតាមមាត្រា៩៣ មាត្រា៩៤ មាត្រា១០៧ និង មាត្រា១០៨នៃក្រមព្រហ្មទណ្ឌ។

១២-សាលក្រមព្រហ្មទណ្ឌលេខ២១«ជ»/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងសំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ហើយ គួរតំកល់ទុកជាបានការ លើកលែងតែចំណុចទី៣ ស្តីពីទណ្ឌកម្មលើជនជាប់ចោទឈ្មោះ[redacted]សុខា ផ្អែកតាមការយល់ឃើញខាងលើ រីឯចំណុចផ្សេងពីនេះ គប្បីតំកល់ទុកជាបានការដដែល។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ក/ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-១០-២០១៣របស់លោក[redacted]



៣១៧

រាជរាជ្យាវង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

ខ/ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-១០-២០១៣របស់ឈ្មោះ[redacted] វិបុល ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

គ/ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១០-១០-២០១៣របស់ឈ្មោះ[redacted] សុខា ទុកជាត្រឹមត្រូវតាមច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២១«ជ»/១០-១០-២០១៣របស់សាលាដំបូងព្រៃវែងទុកជាបានការ លើកលែងតែចំណុចទី៣ ស្ដីពីទណ្ឌកម្មលើឈ្មោះ[redacted] សុខា ចំនួន០២ឆ្នាំ០៦ខែ ត្រូវកែប្រែមកដាក់ទណ្ឌកម្មពន្ធនាគារចំនួន១៣ខែ១៥ថ្ងៃ(ដប់បីខែដប់ប្រាំថ្ងៃ)វិញ រីឯទោសនៅសល់ត្រូវព្យួរធម្មតា។

៣-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០២-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ ជនជាប់ចោទឈ្មោះ[redacted] វិបុល.ឈ្មោះ[redacted] សុខា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះវ៉ា ចិន្តា។

បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់។

**សាលដីកានេះចូលជាស្ថាពរតែចំពោះឈ្មោះ[redacted]វិបុល.**

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ជំពូកជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី ២៨ ខែ 3 ឆ្នាំ២០១៤

**បានឃើញ**
**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]